# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣ សសរ

## សេចក្តីសំរេច

ស្តីពី

## ការបង្កើតគណៈកម្មាធិការការពារតំបន់ទំនប់ការពារ ទឹកប្រៃព្រៃនប់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ

* ※ *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមតម្រូវការចាំបាច់

## សំរេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការការពារតំបន់ទំនប់ការពារទឹកប្រៃព្រៃនប់ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ដែលមាន

សមាសភាពដូចតទៅ :

១. ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២. ឯកឧត្តម ទាវ សារ៉ាវ៉ាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន អនុប្រធាន

៣. ឯកឧត្តម ស៊ូ ស៊ូវ៉ាត់ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

៤. ឯកឧត្តម វ៉ែន សារិន អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អនុប្រធាន

៥. ឯកឧត្តម ឈុន ស៊ីរុន អភិបាលរងទី ១ក្រុងព្រះសីហនុ អនុប្រធាន

៦. លោក ពេជ្រ គឹមសាន្ត ប្រធានមន្ទីរធនធានទឹក និងឧតុនិយមក្រុងព្រះសីហនុ សមាជិក

៧. លោក ម៉ែង សារឿន ប្រធានមន្ទីរបរិស្ថានក្រុងព្រះសីហនុ សមាជិក

៨. លោក នៅ វេតនា ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រុងព្រះសីហនុ សមាជិក

៩. លោក សូ សុខ ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់និងសុរិយោដីក្រុងព្រះសីហនុ សមាជិក

១០. លោក មាស ឧត្តម អភិបាលខណ្ឌព្រៃនប់ សមាជិក

**ប្រការ ២.-**

គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ :

- ចុះស្រាវជ្រាវកំណត់តំបន់តាមបណ្តោយទំនប់ការពារទឹកប្រៃព្រៃនប់ ដោយកំណត់ច្បាស់លាស់លើស្ថានភាពជាក់ស្តែង ដែលគណៈកម្មាធិការនេះមានភារកិច្ចត្រួតពិនិត្យ និងការពារ ដើម្បីស្នើទៅរាជរដ្ឋាភិបាលធ្វើការបង្កកដោយអនុក្រឹត្យ ។

- ចូលរួមសហការជាមួយអាជ្ញាធរដែនដី ទប់ស្កាត់ការកាប់បំផ្លាញព្រៃតាមបណ្តោយតំបន់ទំនប់ ធានាបាននូវស្ថានភាពបរិស្ថាន ប្រកបដោយនិរន្តរភាព ដើម្បីអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយដីធ្លីតំបន់ហាមឃាត់អោយបានល្អប្រសើរ ។

- ចលនាប្រជាពលរដ្ឋចូលរួមថែរក្សា ការពារព្រៃ និងដាំដើមឈើឡើងវិញក្នុងតំបន់នេះ ដោយគូសបញ្ជាក់អំពីសារៈសំខាន់របស់ព្រៃឈើ ដើម្បីការពារទំនប់ និងមច្ឆជាតិ ។

**ប្រការ ៣.-**

គណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ ហើយត្រូវរាយការណ៍ពីលទ្ធផលការងាររបស់ខ្លួនជូនទៅរាជរដ្ឋាភិបាល ។ គណៈកម្មាធិការនេះ មានទីស្នាក់ការនៅក្រសួងធនធានទឹក និងឧតុនិយម និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលក្រុងព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**អន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ